


**ខចែង និងលក្ខខណ្ឌនៃប្រូម៉ូសិនរបស់ CUBC និង Total Energies**

**រយៈពេលនៃប្រូម៉ូសិន**

ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២៥ ដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២៥

**លក្ខណៈសម្បត្តិ និង សិទ្ធិមុនពេលចូលរួម**

ប្រូម៉ូសិននេះផ្តល់ជូនសម្រាប់

- អតិថិជនថ្មី និងអតិថិជនចាស់ របស់ CUBC ទាំងអស់ដែលប្រើប្រាស់ CUBC mBanking App ។
- បុគ្គលិករបស់ CUBC ក៏មានសិទ្ធិចូលរួមក្នុងប្រូម៉ូសិននេះផងដែរ។

**រង្វាន់**

CUBC នឹងផ្តល់ទឹកប្រាក់ត្រលប់មកវិញជាប្រចាំខែក្នុងអំឡុងពេលប្រូម៉ូសិនដល់អតិថិជនដែលប្រើប្រាស់ CUBC QR Pay របស់ CUBC mBanking App ដើម្បីស្កេន និងទូទាត់ប្រាក់ទៅ KHQR នៃធនាគារណាមួយ នៅគ្រប់ស្ថានីយ ឬម៉ាតរបស់ TotalEnergies ។ ប្រតិបត្តិការនីមួយៗនឹងបង្កើតជាលេខ Hash ដែលឈ្មោះតែមួយគត់(HASH#) ដូចខាងក្រោម៖

- **លេខគូពីរខ្ទង់** សំដៅលើលេខគូ នៅខ្ទង់ទី៧ និងទី៨ នៃលេខ Hash នឹងទទួលបានទឹកប្រាក់ត្រលប់មកវិញ ១០០ ភាគរយ ដែលមានអតិបរមារហូតដល់ ២.០០ ដុល្លារ។

| |
|---|
| (ឧទាហរណ៍៖ HASH# -368b42 **33** … )<br><br>• **លេខគូបីខ្ទង់** សំដៅលើលេខបីខ្ទង់ នៅខ្ទង់ទី៦ ទី៧ និងទី៨ នៃលេខHash នឹងទទួលបានប្រាក់ត្រលប់មកវិញ ១០០ ភាគរយ ដែលមានអតិបរមារហូតដល់ ៥០.០០ ដុល្លារ។<br><br>(ឧទាហរណ៍៖ HASH# -368b4 **333** … ) |
| **ជំហានដើម្បីទទួលបានរង្វាន់**<br><br>• អតិថិជនទៅស្ថានីយប្រេងឥន្ធនៈ/ម៉ាតរបស់ TotalEnergies ឬហាង/កាហ្វេ Bonjour<br>• អតិថិជនចាក់ប្រេងឥន្ធនៈ ឬប្រើប្រាស់សេវាកម្មផ្សេងៗ<br>• អតិថិជនប្រើប្រាស់ CUBC QR Pay របស់ CUBC mBanking App ដើម្បីស្កេន និងទូទាត់ប្រាក់ទៅ KHQR នៃធនាគារណាមួយ នៅគ្រប់ស្ថានីយ ឬម៉ាតរបស់ TotalEnergies ដែល KHQR មានឈ្មោះ "TOTAL" និង/ឬ ស្ថានីយផ្សេងៗដែលបានជ្រើសរើសក្នុងបញ្ជីកិច្ចសហប្រតិបត្តិការរវាង TEMC និង CUBC ដែលមិនមានឈ្មោះ "TOTAL" ជាឈ្មោះ KHQR ដោយមានរាយក្នុងតារាងនៅខាងក្រោម ។<br>• ប្រតិបត្តិការបានបញ្ចប់ដោយជោគជ័យ (បន្ទាប់ពីដំណើរការទូទាត់ប្រាក់ត្រូវបានបញ្ចប់ និងបង្ហាញថា "ជោគជ័យ" នៅលើ App ជាមួយនឹងសេចក្តីសង្ខេបនៃប្រតិបត្តិការ)<br>• អតិថិជនអាចពិនិត្យមើលលេខសម្គាល់នៃប្រតិបត្តិការ ដើម្បីដឹងថាអតិថិជនឈ្នះលេខ HASH# ជាលេខគូពីរខ្ទង់ ឬលេខគូបីខ្ទង់<br>• នៅចុងខែបន្ទាប់ CUBC នឹងប្រកាសអ្នកឈ្នះនៅក្នុងបណ្តាញសង្គមផ្លូវការរបស់ CUBC និង សារSMS ហើយផ្ទេរប្រាក់រង្វាន់ដល់អ្នកឈ្នះទាំងអស់តាមគណនី CUBC របស់អតិថិជនស្របតាមខថែង និងលក្ខខណ្ឌដូចខាងក្រោម |

**ខចែង និងលក្ខខណ្ឌ**

- ប្រតិបត្តិការនីមួយៗអាចបង្កើតលេខ Hash ពិសេសតែមួយគត់។ លេខ Hash ដែលឈ្នះនឹងទទួលបានទឹកប្រាក់ត្រលប់តែម្តងប៉ុណ្ណោះ ហើយលេខ Hash ដដែលស្ទួនគ្នានឹងចាត់ទុកជាមោឃៈ។
- ចំនួនប្រាក់រង្វាន់ដែលឈ្នះមិនមានដែនកំណត់ទេ អតិថិជនកាន់តែប្រើគណនី CUBC ដើម្បីស្កេន និងទូទាត់ប្រាក់នៅស្ថានីយប្រេងឥន្ធនៈ TOTAL ឬម៉ាត នោះនឹងមានឱកាសឈ្នះរហូតដល់ ១០០ ភាគរយ នៃទឹកប្រាក់ត្រលប់មកវិញជាអតិបរមារហូតដល់ ៥០.០០ ដុល្លារ។
- ចំនួនទឹកប្រាក់អប្បបរមាក្នុងមួយប្រតិបត្តិការគឺ ១.០០ ដុល្លារអាមេរិក ឬស្មើនឹងប្រាក់រៀលខ្មែរ (៤០០០.០០ រៀល)។
- CUBC រក្សាសិទ្ធិក្នុងការត្រួតពិនិត្យប្រតិបត្តិការក្នុងករណីដែលមានបញ្ហាមិនប្រក្រតីណាមួយកើតឡើង។ ប្រតិបត្តិការដែលមានសិទ្ធិចូលរួមប្រូម៉ូសិនបាន លុះត្រាតែអតិថិជនប្រើ CUBC mBanking App ដើម្បីស្កេន KHQR នៅ TOTALEnergies ណាមួយមានកំណត់អត្តសញ្ញាណឈ្មោះ "TOTAL" នៅតាមទីតាំងរបស់ស្ថានីយ ឬឈ្មោះហាង (ឧទាហរណ៍៖ TOTAL *Monivong* ឬហាង Bonjour) និងស្ថានីយផ្សេងៗដែលបានជ្រើសរើសនៅក្នុងបញ្ជីកិច្ចសហប្រតិបត្តិការរវាង TEMC និង CUBC ដែលមិនមានឈ្មោះ "TOTAL" ជាឈ្មោះ KHQR ដោយមានរាយក្នុងតារាង "ក" ។ រាល់ប្រតិបត្តិការពី CUBC QR Pay ដែលធ្វើឡើងចំពោះពាណិជ្ជករ TotalEnergies ដែល KHQR មិនមានឈ្មោះ "TOTAL" ឬដូចដែលបានរាយក្នុងតារាង "ក" នឹងមិនត្រូវបានចាត់ទុកថាមានសិទ្ធិទទួលបានរង្វាន់ជាសាច់ប្រាក់នោះទេ។
- កម្មវិធីប្រូម៉ូសិននេះមានសុពលភាពក្នុងអំឡុងពេលផ្តល់រង្វាន់ដល់រយៈពេលបញ្ចប់នៃប្រូម៉ូសិន។ លេខ HASH ដែលឈ្នះក្នុងរយៈប្រូម៉ូសិននឹងត្រូវបានផ្ទេរជាទឹកប្រាក់

ត្រលប់វិញដោយផ្ទាល់ទៅគណនី CUBC របស់អតិថិជននៅខែបន្ទាប់ក្នុងរយៈពេល ២០ ថ្ងៃនៃថ្ងៃធ្វើការ។

- CUBC នឹងដកសិទ្ធិ ឬចាត់វិធានការផ្លូវច្បាប់ ប្រសិនបើអ្នកចូលរួមបំពានលើខចែង និងលក្ខខណ្ឌ ហើយមានចេតនាក្នុងការកេងប្រវ័ញ្ចប្រូម៉ូសិននេះដោយមធ្យោបាយណាមួយ។

- CUBC រក្សាសិទ្ធិក្នុងការត្រួតពិនិត្យប្រតិបត្តិការ និងស៊ើបអង្កេតរាល់បញ្ហាមិនប្រក្រតីដែលអាចកើតឡើងក្នុងអំឡុងពេលប្រូម៉ូសិននេះ។

- រាល់ការចំណាយដែលកើតឡើងនៅក្នុងប្រូម៉ូសិននេះ ដោយផ្អែកលើការឈ្នះរង្វាន់ រួមទាំងពន្ធ ការដឹកជញ្ជូន និងការគិតថ្លៃផ្សេងទៀតជាទំនួលខុសត្រូវរបស់អតិថិជនដែលឈ្នះ ។

- តាមរយៈការចូលរួមប្រូម៉ូសិននេះ អតិថិជន និង/ឬអ្នកឈ្នះបានយល់ព្រមផ្តល់សិទ្ធិឱ្យធនាគារមានសិទ្ធិក្នុងការបង្ហោះឈ្មោះ និងរូបថតរបស់អ្នកឈ្នះនៅក្នុងបណ្តាញសង្គម និងផ្សព្វផ្សាយជាសាធារណៈ។
- ការខកខានក្នុងការអនុវត្តតាមប្រការដែលបានចែងរបស់ CUBC និង TotalEnergies ខាងលើនឹងត្រូវចាត់ទុកជាមោឃៈហើយគ្មានការផ្តល់ជាប្រាក់ឬវត្ថុជំនួសនឹងផ្តល់ជូនទាំងស្រុងឬដោយផ្នែកឡើយ។

- កម្រិតដែលអនុញ្ញាតដោយច្បាប់ និងបទប្បញ្ញត្តិ និងដើម្បីការពារផលប្រយោជន៍អាជីវកម្មស្របច្បាប់របស់ សាជីវកម្មធនាគារកាថេយូណៃធីត (កម្ពុជា) ចំកាត់ យើងខ្ញុំសូមរក្សាសិទ្ធិគ្រប់យ៉ាងក្នុងការសម្រេចចិត្តបញ្ចប់កម្មវិធីប្រូម៉ូសិន ព្រមទាំងការផ្លាស់ប្តូរបន្ថែម ឬលុបចោលទៅលើលក្ខខណ្ឌនានាដោយមិនចាំបាច់មានការជូនដំណឹងជាមុន ឬការយល់ព្រមពីអតិថិជន។

- សាជីវកម្មធនាគារកាថេយ្យូណៃធីត (កម្ពុជា) ចំកាត់ រក្សាសិទ្ធិក្នុងការបកស្រាយបញ្ហាណាមួយដែលមិនត្រូវបានបានចែងក្នុងលក្ខខណ្ឌនេះ។
- សាជីវកម្មធនាគារកាថេយ្យូណៃធីត (កម្ពុជា) ចំកាត់ នឹងខិតខំប្រឹងប្រែងដោះស្រាយវិវាទណាមួយដែលអាចកើតឡើងទាក់ទងនឹងការប្រូម៉ូសិននេះ ឱ្យអស់ពីលទ្ធភាពស្របតាមគោលការណ៍របស់ធនាគារ ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ www.cathaybk.com.kh/ ឬទាក់ទងអតិថិជនរបស់យើងខ្ញុំតាមតាមរយៈលេខទូរសព្ទ៖ ០២៣ ៨៨ ៥៥ ០០ / ០៦៩ ៨៨ ៥៥ ០០ ។

<u>តារាង "ក" ៖ ស្ថានីយផ្សេងៗដែលបានជ្រើសរើសនៅក្នុងបញ្ជីកិច្ចសហប្រតិបត្តិការរវាង TEMC និង CUBC ដែលមិនមានឈ្មោះ "TOTAL" ជាឈ្មោះ KHQR</u>

| No | Station name | Location | Bank Name |
|---|---|---|---|
| 1 | TotalEnergies Oudong | Kandal | TotalEnergies Oudong |
| 2 | TotalEnergies Kg Cham 2 | Kampong Cham | Total Kampong Cham 2 |
| 3 | TotalEnergies Kratie | Kratie | Total Kratie01 |
| 4 | TotalEnergies Mondulkiri | Mondulkiri | Total Mondulkiri |
| 5 | TotalEnergies Pha Arv | Kampong Cham | Total Ph'av |
| 6 | TotalEnergies Prek Leap | Phnom Penh | Total Prek Leap |
| 7 | TotalEnergies Prek Leap 168 | Phnom Penh | Total Prek Leap168 |
| 8 | TotalEnergies Prek Tameak | Kandal | Total Prektamek |
| 9 | TotalEnergies Rattanakiri | Rattankiri | Total Rattanakiri |
| 10 | TotalEnergies Svay Antor | Prey Veng | Total Svay Anthor |
| 11 | TotalEnergies Century | Phnom Penh | TEMC HQ 4 (CENTURY PLAZA) |
| 12 | TotalEnergies Kg Thom 2 | Kompong Thom | TEMC HQ 1 (KAMPONG THOM) |
| 13 | TotalEnergies Kg. Cham | Kampong Cham | TEMC HQ 2 (PP) |
| 14 | TotalEnergies Makara | Phnom Penh | TEMC HQ 3 (PP) |
| 15 | TotalEnergies Chamka Dong | Phnom Penh | BONJOUR CHAMKA DOUNG |
| 16 | TotalEnergies Choeung Ek | Phnom Penh | PANHARITH DENG |
| 17 | TotalEnergies Prey Sor | Phnom Penh | BONJOUR 2004 |
| 18 | TotalEnergies Road 2004 | Phnom Penh | BONJOUR 2004 |

| | | | |
|---|---|---|---|
| 19 | TotalEnergies ROAD 50M | Phnom Penh | MART BONJOUR MP 50M |
| 20 | TotalEnergies TEP PHAN | Phnom Penh | SIM SOKRITH 1 |
| 21 | TotalEnergies Toul Kei | Phnom Penh | BONJOUR TOUL KEI |
| 22 | TotalEnergies Veng Sreng 2 | Phnom Penh | Chhormsopheak OUCH |
| 23 | TotalEnergies Kampongsom | Sihanok Ville | BONJOUR 2004 |
| 24 | TotalEnergies Road 41 | Kampong Speu | TOTALENERGIES ROAD 41 B |
| 25 | TotalEnergies Takeo | Takeo | CHEAK CHANSOVAN ROATH |
| 26 | TotalEnergies  POIPET | Banteay Mean Chey | KET SOPHAT |
| 27 | TotalEnergies Bombek Leach | Pursat | ស្ថានីយ៍បំបែកលាច |
| 28 | TotalEnergies Kg. Chhnang | Kampong Chhnang | ឃឹម វុទ្ធី |
| 29 | TotalEnergies KOMPONG THOM | Kompong Thom | NUN VYRAK |
| 30 | TotalEnergies Odormeanchey | Oddar Meanchey | HACH SOKONG |
| 31 | TotalEnergies Pailin | Pailin | CHHANN PHEA |
| 32 | TotalEnergies Preah Vihear | Preah Vihea | CHHANN PHEA PVH |
| 33 | TotalEnergies Siem Reap I | Siem Reap | ENG PHA 1<br>ENG PHA |
| 34 | TotalEnergies Siem Reap II | Siem Reap | HORT RACHNA 3<br>SR 2 by R.HORT<br>SR 2 KHR by R.HORT<br>HORT RACHNA |
| 35 | TotalEnergies Siem Reap III | Siem Reap | THACH SAM ORN |
| 36 | TotalEnergies Siem Reap IV | Siem Reap | YAN PONLORK 1 |